គណបក្ស សម រង្ស៊ី
SAM RAINSY PARTY
PARTI SAM RAINSY
សីលធម៌ សច្ចធម៌ យុត្តិធម៌

# សារលិខិត

## ប្រគេន ជូនព្រះសង្ឃ និងបងប្អូនជនរួមជាតិខ្មែរកម្ពុជាក្រោម

*ជាទីសក្ការៈ និងជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ*

ខ្ញុំ ព្រះករុណាខ្ញុំ សម រង្ស៊ី អ្នកតំណាងរាស្ត្រ និងជាប្រធានគណបក្ស សម រង្ស៊ី សូមសំដែងនូវការគោរព និងកោតសរសើរដោយស្មោះចំពោះវីរភាពដ៏អង់អាចក្លាហាន នៃវីរកុលបុត្រកុលធីតាខ្មែរកម្ពុជាក្រោម ដែលបានតស៊ូប្តូរជីវិតនៅគ្រប់សម័យកាលក្នុងបុព្វហេតុការពារពូជសាសន៍ សាសនា សិល្បៈ វប្បធម៌ អក្សរសាស្ត្រ និងទំនៀមទម្លាប់ប្រពៃណីជាតិខ្មែរ ឲ្យបានគង់វង្សរហូតសព្វថ្ងៃ ។ គំរូវីរភាពដ៏អង់អាចក្លាហាននេះជាសារមួយដ៏សំខាន់សំរាប់ដាស់តឿន ក្រើនរំលឹកដល់ស្មារតីកូនខ្មែរគ្រប់រូបឲ្យភ្ញាក់ក្រោកឡើងតស៊ូការពារបូរណភាពទឹកដីនៃមាតុភូមិអង្គរដ៏បវរនៃយើង ឲ្យបានស្ថិតស្ថេរជាអមតៈ ។ ខ្ញុំយល់ច្បាស់ណាស់ថា គ្មានអ្វីឈឺចាប់ជាងការបាត់បង់មាតុភូមិ និងក្លាយខ្លួនជាជនជាតិភាគតិចនៅលើទឹកដីកំណើតរបស់ខ្លួននោះទេ ។

ក្នុងនាមអ្នកតំណាងរាស្ត្រខ្មែរ និងជាប្រធានគណបក្ស សម រង្ស៊ី ខ្ញុំសូមសំដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះការតស៊ូស្របច្បាប់របស់ព្រះសង្ឃ និងបងប្អូនជនរួមជាតិខ្មែរកម្ពុជាក្រោម ក្នុងការទាមទារសិទ្ធិសេរីភាពរបស់ខ្លួន ទាំងនៅព្រះរាជាណាចក្រកម្ពុជា ទាំងនៅកម្ពុជាក្រោម ព្រោះនេះជាសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប ដែលមានចែងនៅក្នុងសន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា ព្រមទាំងសេចក្តីថ្លែងការណ៍នានា ជាអន្តរជាតិ ស្តីអំពីសិទ្ធិមនុស្ស ។

ទន្ទឹមនឹងនេះ ខ្ញុំថ្កោលទោសយ៉ាងដាច់អហង្កាចំពោះការរំលោភបំពានសិទ្ធិសេរីភាពមកលើព្រះសង្ឃ និងបងប្អូនជនរួមជាតិខ្មែរកម្ពុជាក្រោមរបស់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ទាំងនៅព្រះរាជាណាចក្រកម្ពុជា ទាំងនៅកម្ពុជាក្រោម (បច្ចុប្បន្នសាធារណរដ្ឋសង្គមនិយមវៀតណាមប៉ែកខាងត្បូង) ហើយខ្ញុំចូលរួមជានិច្ចដើម្បីការពារសិទ្ធិសេរីភាពរបស់បងប្អូន ។

ជាមួយគ្នានេះដែរ ខ្ញុំសូមអំពាវនាវយ៉ាងទទូចដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មេត្តាផ្តល់សិទ្ធិពេញលេញជាពលរដ្ឋខ្មែរដល់ប្រជារាស្ត្រ និងព្រះសង្ឃខ្មែរកម្ពុជាក្រោម ស្របតាមរដ្ឋធម្មនុញ្ញមាត្រា៣៣ និងច្បាប់សញ្ជាតិ មាត្រា២, មាត្រា៣ និងមាត្រា៤ ។

សូមព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិខ្មែរកម្ពុជាក្រោមទាំងអស់ ព្រះមេត្តា និងមេត្តាទទួលនូវសេចក្តីគោរព និងស្រឡាញ់ដ៏ជ្រាលជ្រៅបំផុត អំពីខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧*

សម រង្ស៊ី
អ្នកតំណាងរាស្ត្រ
ប្រធានគណបក្ស សម រង្ស៊ី

ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphq@online.com.kh, srpcabinet@online.com.kh, Website : samrainsyparty.org